- ២ -

# ពន្លកផ្កា គ្រួសារអភ័ព្វ

**ម៉ារីណា** បូផារងគ្រោះដោយអំពើហិង្សាដ៏ព្រៃផ្សៃបំផុត តែង បានចងចាំតាមសំដីរបស់អ្នកស្រី ឆាយ សារឿន ជាម្ដាយតាំងពីតូចមកថា នាងបានកើតនៅថ្ងៃ ១៥ រោជ ខែ ភទ្របទ គឺខែភ្ជុំបិណ្ឌ ក្នុងឆ្នាំ១៩៨៣ ចំលើថ្ងៃព្រហស្បត្តិ នៅក្នុងឃុំមួយជាយទីរូមខេត្ត បាត់ដំបង គឺឃុំអន្លង់វិល ស្រុកសង្កែជាទឹកដីជាប់ព្រំដែន កម្ពុជា- ថៃ ។

នៅរាត្រីដែលព្រលឹងនាងបានមកយោនយកកំណើតក្នុងផ្ទៃ អ្នកស្រី ឆាយ សារឿន បានយល់សុបិនឃើញដូចជារូបគាត់ជាមួយលោក តាត សុខុន ជាប្ដី ធ្វើដំណើរទៅក្នុងព្រៃជ្រៅមួយដែលមានទិដ្ឋភាពជ្រោះជ្រងជ្រលង ដងអូរជាទីមនោរម្យសមសាន្តស្ថានស្ងាត់ គង់ចាត់ប្រៀបដូចវិមានព្រៃហេម-ពាន្តនៅក្នុងរឿងព្រេងនិទានបូរាណខ្មែរ ។

ព្រលឹងអ្នកទាំងពីរ បានដើរទៅដល់មុខមហាចេតីយ៍មួយដ៏ធំស្កឹម-ស្កៃដែលហ៊ុំពទ្ធ័ដោយពន្លឺឆព្វណ្ណរង្សី ស្រាប់តែប្រទះឃើញកំណាប់ប្រាក់ជា ច្រើនរយពាន់ដុំផុះចេញពីក្នុងបាតចេតីយ៍នោះមក ប្រកបដោយពណ៌ស្វៃ ពណ៌ខៀវ ដែលមានលក្ខណៈដូចជាកំណាប់នោះគេកប់ទុករាប់រយពាន់ឆ្នាំ មកហើយ ។

ពេលដែលប្រទះឃើញកំណាប់ប្រាក់ផុះមកនៅពីមុខ ពោរពាស

ដូច្នេះ ព្រលឹងអ្នកស្រី ឆាយ សារឿន និង ប្តី បានឱ្យបខ្សែវត្តាដោយរំភើប ត្រេកអរថា « នេះជាកំណាប់ព្រេងដែលឥន្ទព្រហ្មទេវតាប្រទានឱ្យយើងហើយ ចាប់តាំងពីថ្ងៃនេះទៅ យើងលែងក្រហើយ . . . » ។

ទន្ទឹមពេលព្រលឹងអ្នកទាំងពីរគិតគ្នានោះ ស្រាប់តែមានផ្គរលាន់រន្ទះ ក្នុងក្តាំងលាន់រំពងផ្ទៃមេឃ ហើយដុំប្រាក់ទាំងអស់ ដែលកាលពីមុននេះបន្តិច មិនសូវជាមានពន្លឺប៉ុន្មាន ក៏ប្រែក្លាយជាចែងចាំងដូចរស្មីនិលពេជ្រចរណៃ ធ្វើឱ្យអ្នកទាំងពីរកាន់តែមានទឹកចិត្តពុះពោរស្ងប់ស្ងែងពន់ប្រមាណ ។

ជូនជាព្រលឹងអ្នកស្រី ងាកមើលទៅទិសខាងលិចឃើញមានបល្ល័ង្ក ព្រះដ៏ធំមួយស្មើរកំពស់ចេតិយ៍នោះដែរ និង មានរូបព្រះពុទ្ធបដិមារដែលមាន ពណ៌លឿងរន្ទាលឆ្អិនឆ្អៅដូចមាសសុទ្ធ ។ ប៉ុន្តែ មួយភ្លែតនោះព្រះពុទ្ធបដិមារ ក៏ប្រែក្លាយជារូបក្មេងប្រុស ដ៏ស្អាតប្រិមប្រិយ៍ម្នាក់ក្នុងវ័យប្រមាណ ១៥ ឆ្នាំ ដើរចុះពីបល្ល័ង្កព្រះសំដៅមករកគាត់ ។ ក្មេងប្រុសនោះស្លៀកផាមួងពណ៌ សំបកមង្ឃុត ហើយពាក់អាវសកត្រង់ ពាក់ស្បែកជើងឃ្លុប ស្រោមជើងខ្មៅ និង សិតសក់វែកចំហៀងទៅខាងស្តាំ ដើរយឺតៗដោយទឹកមុខញញឹម ប្រិមប្រិយ៍ ។ ព្រលឹងអ្នកស្រីមើលទៅក្មេងនោះគួរឱ្យស្រលាញ់ណាស់ ហើយ ក្មេងនោះ ក៏ដើរដោយគ្មាននិយាយអ្វីមួយម៉ាត់រលាយចូលមកក្នុងខ្លួន អ្នកស្រីទៅ ។...

បន្ទាប់ពីសុបិនឃើញហេតុភេទចម្លែកនោះ អស់រយៈពេល១០ថ្ងៃ ក្រោយមក អ្នកស្រី ឆាយ សារឿន ក៏ចាប់ផ្តើមដឹងថា ខ្លួនមានផ្ទៃពោះ ដោយសារអាការៈរហិតរហៃរបៀបជាចាញ់កូន ហើយចង់ស៊ីតែម្ជូរ ដូចជាម្ជូរ

ស្វាយជាដើម ។

លុះដល់គំរប់ខែថ្ងៃដែលត្រូវសំរាល គឺសំរាលបានម៉ារីណាដែលជាភេទស្រីទៅវិញ វាផ្ទុយគ្នាពីក្នុងសុបិន ដែលឃើញយុវជនប្រិមប្រិយ៍ដើរចូលមកក្នុងផ្ទៃរបស់គាត់ ទំនងព្រលឹងកូនប្រុសមកយកកំណើត ។ ទោះបីយ៉ាងនេះក្តី ក៏ម៉ារីណាកើតមកមានរូបឆោមលោមពណ៌គួរឱ្យស្រលាញ់ណាស់ គឺថ្លោសត្រលុក១ អ្នកណាឃើញក៏ចង់បីពរដែរ ។

កាលនៅអំឡុងឆ្នាំ ១៩៨៣ នោះ នៅខេត្តបាត់ដំបងមានសភាពការណ៍វឹកវរណាស់ ពួកខ្មែរក្រហមធ្វើសកម្មភាពស្ទើរគ្រប់ទីកន្លែង ។ អាជ្ញាធរខេត្ត បានចេញប្រកាសមិនឱ្យឯកជនប្រើប្រាសម៉ូតូធុនធំដែលមានល្បឿនលឿនខ្លាំងនោះឡើយ ព្រោះខ្លាចធ្លាក់ក្នុងឧបាយកលរបស់ខ្មាំង វាទិញយកទៅធ្វើសកម្មភាពវិទ្ធង្សនាផ្សេង១ ទល់និងរដ្ឋអំណាចបដិវត្តន៍ ទើបយុទ្ធនាការរឹបអូស ឬប្រមូលទិញយកវត្ថុទាំងនោះ មកទុកគ្រប់គ្រងរបស់អាជ្ញាធរខេត្ត ក៏ចាប់ផ្តើមឡើងយ៉ាងតឹងតែងនៅគ្រប់ទីកន្លែងទាំងអស់ ។

លោក តាត សុខុន ដែលជាឪពុកម៉ារីណា ក្រោយពីខំរកស៊ីនៅឯឃុំត្រែងក្នុងស្រុករតនៈមណ្ឌល ( ប៉ៃលិន ) សន្សំលុយកាក់ទិញបានម៉ាស៊ីនភ្លើង និង ម៉ូតូធុនធំ ពីរ បី គ្រឿង ព្រោះគាត់ជាអ្នកជំនាញខាងជួសជុលគ្រឿងម៉ាស៊ីនម៉ូតូស្រាប់ ក៏ត្រូវរដ្ឋអំណាចដកហូតយកសម្ភារៈទាំងនោះដោយស្វ័យប្រវត្តិ ។

កាលណោះ ទោះបីជាមានការទូទាត់ជាតំលៃសម្ភារៈសងមកវិញក្នុងជីវិតណាមួយក្តី ក៏គ្រួសារម៉ារីណាត្រូវធ្លាក់ចុះក្នុងវិបត្តិសេដ្ឋកិច្ចយ៉ាង

ធ្ងន់ធ្ងរ ព្រោះជីវភាពប្រចាំថ្ងៃពឹងពាក់តែលើសម្ភារៈទាំងនោះ ។ ដោយពីមួយថ្ងៃទៅមួយថ្ងៃការរកស៊ីនៅឃុំអន្លង់រិល ហាក់ដូចជាមិនអំណោយផលសំរាប់គាត់ ទើបលោក តាត សុខុន និង អ្នកស្រី ឆាយ សារឿន បានសំរេចចិត្តនាំកូនស្រីតូចៗបួននាក់ រួមទាំង ម៉ារីណា ផង ដែលនាងទើបបានអាយុ៤ខែមករស់នៅទីក្រុងភ្នំពេញ ដោយសំណាក់នៅផ្ទះលោក គង្គ ប៊ុនឈឿន និង អ្នកស្រី តាត គិមលន ដែលត្រូវជាប្អូនថ្លៃ និង ប្អូនបង្កើត ។

នៅទីនោះ ដើម្បីប្រយុទ្ធតស៊ូចិញ្ចឹមគ្រួសារ អ្នកស្រី ឆាយ សារឿន ជាម្តាយ ម៉ារីណា ក៏បានធ្វើនំចំណី ដូចជា ចាហួយខ្មៅ និង ស្ងោរសណ្តែកបាយលក់នៅអែបរបងសាលាអប់រំកាយ និង កីឡា ដែលកាលណោះនៅជាសាលានយោបាយនៃក្រសួងឃោសនាការវប្បធម៌ និង ពត៌មាន ។

ចំណែកលោក តាត សុខុន ក៏មិនទំនេរដែរ ដោយគាត់ប៊ិនប្រសប់ខាងគ្រឿងម៉ាស៊ីន ខ្ជាប់ខ្ជួន មួយថ្ងៃៗ គាត់តែងចាកចេញពីផ្ទះរហូតដល់ព្រលប់ ទើបត្រឡប់ចូលវិញ ដើម្បីទៅសហការជួសជុលម៉ាស៊ីនកង់ម៉ូតូជាមួយមិត្តភ័ក្តិខ្លះដែលធ្លាប់ស្គាល់ហើយ ដែលគេមានទីតាំងនៅភ្នំពេញមុន ។

អស់រយៈជាច្រើនខែ មុខរបរអម្រស់អម្រទាំងនេះមិនអាចផ្តល់នូវសុភមង្គលសំរាប់គ្រួសារកំសត់នេះបានគ្រប់គ្រាន់ឡើយ គឺ ចំណូលប្រផុតប្រផើយបានគ្រប់តែមួយថ្ងៃៗប៉ុណ្ណោះ វាមិនខុសពីគ្រួសារលោក គង្គ ប៊ុនឈឿន ដែរ គឺសុទ្ធតែក្រខ្សត់ ទុរគតដូចគ្នា ទោះបីកាលណោះ លោកនេះមានតំណែងសំខាន់នៅក្នុងនាយកដ្ឋានភាពយន្តក៏ដោយ ។ ប្រពន្ធ លោកគង្គ ប៊ុនឈឿន ក៏លក់ដូរនំចំណីបន្តិចបន្តួចនៅមុខផ្ទះ ដូចជា បារី និង ផ្លែឈើ

ផ្សេងៗ គ្រាន់បានកំរៃប្រចាំថ្ងៃទប់ឆ្នាំង ព្រោះលោកជាប្តី ទំនងជាមិនចេះស្វែងរកចំណូលជាលាភសក្ការៈផ្សេងៗនៅក្នុងតួនាទី ក្រៅពីប្រាក់ខែសុទ្ធៗនោះឡើយ ។

អាស្រ័យដោយមើលឃើញថា គ្រួសារទាំងពីរសុទ្ធតែមានកូនច្រើន ហើយលំបាកទល័ក្រដូចគ្នាមិនអាចអ្នកណាយោងអ្នកណារួច អ្នកស្រីតាត គិមឡេង ដែលត្រូវជាប្អូនទី៤របស់លោក តាត សុខុន ក៏បានហៅបងទាំងពីរឱ្យនាំកូនៗទៅនៅជាមួយវិញ គឺផ្ទះនៅម្តុំបរិវេណមជ្ឈមណ្ឌលផ្តល់ឈាមក្រោយសាលាយុគន្ធរ ព្រោះនាងមេម៉ាយប្តីស្លាប់ចោលនៅសម័យប៉ុលពតមានតែកូនពីរនាក់ក្នុងបន្ទុក ។

នៅទីនោះអ្នកស្រី ឆាយ សារឿន អាចមានកន្លែងលក់ដូរនំចំណើបានកាក់កបជាងនៅកន្លែងដើម ហើយក៏ជិតកន្លែងដែល លោក តាត សុខុន ប្រកបរបរជួសជុលកង់ម៉ូតូដែរ ។

ដោយពិតនោះ លោកតាត សុខុន ក៏មានចំណេះវិជ្ជាសមរម្យនឹងអាចធ្វើការបំរើរដ្ឋបានដែរ ប៉ុន្តែ ដោយលោកមានទស្សនៈវិស័យជាមនុស្សឯករាជ្យ មិនសូវចង់នៅក្រោមការត្រួតត្រារបស់អ្នកណា គាត់ក៏សុខចិត្តរស់នៅរកស៊ីតាមសមត្ថភាពជំនាញរបស់គាត់ទៅ ។

រស់នៅត្រដាបត្រដួសរហូតដល់ ម៉ារីណា បានអាយុ ៩ខែ លោកតាត សុខុន រំពឹងគិតថា មុខរបរជាអ្នកជួសជុលម៉ូតូដូច្នេះ មិនមានការជឿនលឿនទៅមុខ ក៏ដាច់ចិត្តសុំលាអ្នកស្រី ឆាយ សារឿន ជាភរិយាទៅធ្វើជាជាងជួសជុល និង បរឡានដឹកឈើហ៊ុបឱ្យក្រុមហ៊ុនឯកជនមួយ នៅឯ

កំពង់សោម ដោយផ្ដល់លុយកាក់ដែលរកបាននោះជាហូរហែមកឱ្យអ្នកស្រី ឆាយ សារឿន ចិញ្ចឹមកូនទាំង ៤ ។

ចំណែកអ្នកស្រីជាភរិយាវិញ បន្ទាប់ពីលក់នំចំណីនៅក្បែរផ្ទះមិនបានលទ្ធផលល្អប្រសើរក៏បានដូរមុខរបរ គឺតស៊ូទៅលក់ អំពៅជាមួយបុរសម្នាក់ឈ្មោះ សារិន ស្រេង ដែលត្រូវជាកូនក្មួយធ្លាប់នៅស្រុកជាមួយគ្នា ។ ការទិញអំពៅមកលក់នេះ គឺមិនមែនមកចាំទិញនៅមាត់ទន្លេម្ដុំមុខវត្តឧណ្ណាឡោមនោះទេ គឺត្រូវធ្វើដំណើរតាមកាណូតជាមួយជននោះចុះឡើងរហូតដល់ស្រុកចំការនៅតាមដងទន្លេខេត្តកំពង់ចាម ដើម្បីទៅម៉ៅអំពៅពីចំការយកមកបោះឱ្យគេ ។

ពេលនោះអ្នកស្រី ឆាយ សារឿន មិនអាចទុក ម៉ារីណា ឱ្យនៅជាមួយអ្នកណាបានឡើយ ព្រោះនាងទើបបានអាយុ៩ខែ នៅបៅដោះជាប្រចាំរាល់ថ្ងៃ គឺគាត់តែងយកនាងទៅជាមួយហើយ កំពៀកចុះឡើងគួរឱ្យអាណិតពន់ប្រមាណ ។

មានពេលខ្លះ នៅពេលទៅដល់ចំការអំពៅដែលត្រូវម៉ៅទិញ ដោយមិនហ៊ានយកកូនទៅក្នុងចំការខ្លាចមុតស្លឹកអំពៅ ក៏តែងផ្ញើ ម៉ារីណា នៅផ្ទះអ្នកស្រុកដែលនៅជិតៗនោះ ហើយម៉ារីណាដែលនៅជាទារិកាក៏អង្គុយលើរានក្នុងខ្ទមមួយចាំម្ដាយ ដែលចូលទៅក្នុងចំការដើម្បីមើលកម្មករកាប់អំពៅ ។

អ្នកស្រីឆាយ សារឿន តែងបានដំណាលរឿងនេះប្រាប់ លោកគង្គ ប៊ុនឈឿន ជារឿយៗ ពីភាពកម្សត់កម្រកាលដែលគាត់តស៊ូជាមួយកូនតូច

ទៅរកស៊ីទិញអំពៅនៅចំការព្រែកក្របៅនោះ ។ គឺមានថ្ងៃមួយគាត់ចូលទៅក្នុងចំការយូរពេក ព្រោះមេឃជិតភ្លៀងប្រញាប់ឱ្យកម្មករកាប់ឱ្យអស់ ដើម្បីជញ្ជូនដាក់កាណូតឱ្យទាន់ពេលដែលត្រូវត្រឡប់មកវិញ ក៏ចោល ម៉ារីណា នៅលើរានក្នុងខ្ទមនោះយូរជិត៧-៨ម៉ោង នាងក៏យំស្ទើរខះបំពង់កដោយឃ្លានពៅ ។

មានគេរត់ទៅប្រាប់ថា កូនយំខ្លាំង អ្នកស្រីឆាយ សារឿន ក៏រត់មករកកូនវិញទាំងកណ្តាលព្យុះខ្យល់បោកបក់ ហើយអាណិតកូនរហូតដល់មានទឹកភ្នែកហូរមកសស្រាក់ ព្រោះពេលនោះ ក្រោយពីឃើញម្តាយ ម៉ារីណា ដែលយំហៀរទឹកភ្នែកទឹកសំបោរ ក៏បក់ដៃខ្វៃៗមករកម្តាយក្នុងទឹកមុខពោរពេញដោយក្តីស្រេកឃ្លាន ។

អ្នកស្រី សារឿន ប្រញាប់លើកកូនបីពរលួងលោមឱ្យបៅ ហើយនឹកសង្វេគខ្លួនថា នេះហេតុតែខ្លួនក្រខ្សត់លំបាកវេទនា ហើយទើបតស៊ូទៅចោលកូនរាប់៧ម៉ោងដូច្នេះ ។ ការពិតអ្នកស្រី សារឿន នៅមានកូនស្រីពនាក់ទៀតដែលមានអាយុពី ៥ ឆ្នាំរហូត ដល់ ១០ ឆ្នាំដែរ ប៉ុន្តែហេតុដែលអ្នកស្រីមិនបានយកឱ្យមកជួយមើលប្អូនបាន ព្រោះពួកវានៅជាប់រៀន និង នៅជួយធ្វើការងារម្តាយមីងដែលនៅឯផ្ទះ ទើបត្រដាបត្រដួសតស៊ូម្នាក់ឯងជាមួយកូនតូច ដែលជូនកាលការទទួលអំពៅយកមកលក់នោះក៏មានខាត មានចំណេញមិនទៀងពេលឡើយ ។

អ្នកស្រីតែងតែងើបពីម៉ោង២អាធ្រាតជានិច្ច ដឹកអំពៅតាមកាណូតពីព្រែកក្របៅជាមួយ ម៉ារីណា យកមកភ្នំពេញ ។ ការងារត្រាំត្រែងបាត់

នឿយយ៉ាងនេះ មិនយូរប៉ុន្មានបណ្ដាលឱ្យម៉ារីណាមានជម្ងឺ ព្រោះថៃធូនមិនបានជិតដល់ក៏បណ្ដាលទៅជារាគរូសឈឺស្កាំងស្គម ពោះកំប៉ោង ដូចជាកើតតាន ឬ កើតព្រូន ។

ពេលនោះអ្នកស្រីរំពឹងគិតថា មិនអាចរកស៊ីបែបនេះតទៅទៀតបាន ព្រោះកូនមានជម្ងឺម្យ៉ាងដោយពេលនោះរដូវអំពៅ ក៏ផុតអស់ទៅទើបអ្នកស្រីឈប់សំរាកនៅផ្ទះវិញ ដើម្បីព្យាបាលកូនមួយរយៈ ។

ប៉ុន្តែ បានតែប៉ុន្មានថ្ងៃប៉ុណ្ណោះ អ្នកស្រីមិនអាចនៅទំនេរយូរឡើយ ព្រោះសង្ឃឹមលើប្រាក់ខែប្ដី៤០០០រៀល ដែលទៅធ្វើជាងជួសជុលឡាននៅកំពង់សោមនោះ មិនធូនល្មមឱ្យជីវិតក្រុមគ្រួសាររស់បានឡើយ ទើបនៅពេលដែលម៉ារីណាបានជាសះស្បើយបន្តិច គាត់ក៏ចាប់ផ្ដើមនាំកូនមូរបារីលក់ហើយយកទៅបោះឱ្យម៉ូយនៅមុខពេទ្យចិន មាត់ទន្លេ ផ្សារចាស់ និងមុខស្ថានីយ៍រថភ្លើង ។ កាលពីឆ្នាំ១៩៨៥នោះ ប្រាក់ខែកម្មករម្នាក់៧បាន ៤០០០ រៀលគឺច្រើនណាស់ អ្នកស្រី ឆាយ សារឿនខ្វះខាតខ្លាំង គាត់តែងប្រើកូនស្រីច្បងឈ្មោះ នាង តាត រំចង់ ហៅត្រប់ ឱ្យជិះឡានទៅសុំប្រាក់ខែពីប្ដីយកមកចិញ្ចឹមកូនជារឿយៗ ។

លោក តាត សុខុន តែងតែផ្ដល់ប្រាក់កាស់មកតាមកូនអស់៧ទោះតិចក្ដី ច្រើនក្ដីមិនដែលលាក់ទុកឡើយ ធ្វើយ៉ាងណាឱ្យតែក្រុមគ្រួសារកំសត់បានរស់ ក៏នៅតែមិនចង់រស់បានទៀត បានន័យថា ដំណើរជីវិតគ្រួសារម៉ារីណា ពេលនោះមានភាពលំបាកវេទនាទីបំផុត ។ លុយកាក់ដែលបានមកពីប្ដី ទោះមួយពាន់ ពីរពាន់ ឬ បីពាន់ក្ដី អ្នកស្រីឆាយ សារឿន

មិនដែលប៉ានចាយវាយផ្តេសផ្តាស់ទេ គួបផ្សំទាំងលុយដែលបានពីការមូរបារី លក់ផង អ្នកស្រីសំដៅតែទិញអង្ករ ធ្យូង និងអំបិលប្រហុកត្រីងៀត ត្រីឆ្អើរ ទុកសំរាប់តែផ្គត់ផ្គង់កូន១ប៉ុណ្ណោះ ។

បន្ទាប់ពី ម៉ារីណា បានជាសះស្បើយពីជម្ងឺរាករូសមានសាច់ មាន ឈាមឡើងវិញខ្លះ អ្នកស្រី ឆាយ សារឿន ជាម្តាយ ដោយសារខំប្រឹងធ្វើការ ហត់នឿយពេកក៏មានជម្ងឺស្គាំងស្គមគួបផ្សំ និង គាត់មានទម្ងន់កូនក្រោយ ទៀត ធ្វើឱ្យជីវភាពគ្រួសារកាន់តែដុនដាបមែនទែន ។

ចំណែកលោក តាត សុខុន ក្រោយមក ដោយមិនសូវចុះសំរុងគ្នា ជាមួយប្រពន្ធចៅកែដែលគាត់ទៅស៊ីឈ្នួលធ្វើជាងជួសជុលឡាននោះក៏បានសុំ ឈប់ពីការងារ ហើយវិលមករស់នៅជួបជុំគ្រួសារវិញលើផ្ទះម៉្ញុំប្លុកសេរីភាព ព្រោះគាត់ត្រដាបត្រដួស រកទិញបានកូនខ្ទមនៅលើដំបូលផ្ទះជាន់លើបំផុត ជ្រកនៅវិញ ដោយឈប់នៅជាមួយប្អូនម៉្ញុំខាងក្រោយមជ្ឈមណ្ឌលផ្តល់ឈាម នោះហើយ ។

ដោយអនុលោមតាមពាក្យទំនៀមព្រេងនាយថា « ជួញជិតជាជាង ជួញឆ្ងាយ » លោក តាត សុខុន ក៏សំរេចចិត្តរៀបចំ បើកកន្លែងជួសជុល កង់ម៉ូតូនៅកាច់ជ្រុងផ្លូវមួយប្រប១ ខាងក្រោមប្លុកអាគារដែលក្រុមគ្រួសារ គាត់រស់នៅ ហើយចេះតែខំប្រឹងរកស៊ីចិញ្ចឹមកូនប្រពន្ធរហូតទាល់តែម៉ារីណា អាយុបាន ៤ ឆ្នាំ ។

នៅពេលនោះ ចូលដល់ឆ្នាំ១៩៨៧ ស្រាប់តែមានវិបត្តិហេតុដ៏ សោករន្ធត់មួយបានធ្លាក់មកគ្របសង្កត់គ្រួសារអភព្វនេះ គឺ កុមារី តាត រ៉ចង់

ហៅត្រប់ ដែលជាកូនទីពីរ (១) បានរងគ្រោះថ្នាក់ ត្រូវគ្រាប់កាំភ្លើងស្លាប់នៅពេលដែលដឹកទៅព្យាបាលនៅមន្ទីរពេទ្យ ព្រះសង្ឃមិនបានប៉ុន្មានម៉ោង ។

ឧប្បទ្ទវហេតុនេះ គឺបណ្តាលមកពីនៅល្ងាចនោះ មានពិធីមង្គលការមួយនៅកាច់ជ្រុងមុខរោងកុនម្កុដពេជ្រ ( បច្ចុប្បន្នរង្គសាលថ្មដា ) ហើយមានវង់តន្ត្រីប្រគុំលាន់កងរំពង ធ្វើឱ្យក្មេងៗនៅម្តុំនោះនាំគ្នាទៅឈរអើតមើលរបាំ ។ ជំនាន់នោះ មានកុមារកំព្រាកម្សត់ទុរគតជាច្រើនដែលសេសសល់ពីសង្គ្រាមតែងដើរត្រាច់រង្គត់តាមតុចិន ដើម្បីកាយកាកសំណល់បាយសម្លរដាក់ក្នុងថង់កៅស៊ូ ឬកំប៉ុងយកទៅបរិភោគ ដោយសន្ទុះចិត្តស្រេកឃ្លាន ឱ្យតែមានបុណ្យទាន ឬ មង្គលការនៅទីណាម្តងៗ ។

ចំណែកកុមារី រំចង់ ហៅ ត្រប់ ក៏បានទៅឈរមើលគេប្រគុំភ្លេងលាយឡំជាមួយក្មេងក្មាងដ៏ទៃទៀតដែរ ។ ជាចៃដន្យពេលនោះ មានទាហានពីរបីនាក់ដែលកំពុងអង្គុយរួមតុការ ពេលស្រវឹងខ្លាំងក៏ខឹងឈ្លោះប្រកែកគ្នាឡូឡា ហើយដកកាំភ្លើងដែលដាក់ជាប់ ខ្លួនទៅជាមួយបាញ់គ្នាប្រេវប្រាវ!.។

ហេតុតែទំនាយជីវិតរបស់កុមារីរំចង់ត្រូវអស់ ពេលដែលគេបាញ់គ្នានោះ ស្រាប់តែមានគ្រាប់កាំភ្លើងមួយបានហើរខ្ទាតធ្លាក់មកត្រូវចំថ្ងាស់កុមារីអភ័ព្វ ហើយប្រកាច់ដួលខ្ពោកបាត់មាត់បាត់កភ្លាម ។

នៅថ្ងៃនោះ លោកគង្គ ប៊ុនឈឿន ព្រមទាំងក្រុមគ្រួសារ ក៏បានទៅចូលរួមបុណ្យសពកុមារីរំចង់ ដែលត្រូវជាក្មួយដែរ គឺបន្ទាប់ពីទៅមើលគេដឹកយកសពចេញពីមន្ទីរពេទ្យ ក៏នាំគ្នាទៅឈាបនដ្ឋានវត្តព្រះពុទ្ធមានបុណ្យ

(១) បន្ទាប់ពី សេគុនដូ ហៅ សុខ ជាកូនច្បងនៅអាមេរិក ។

ហើយនិមន្តព្រះសង្ឃបង្សុកូលបូជា សពនាងត្រប់នៅទីនោះភ្លាម ។ ដោយសារគ្រួសារទាំងពីរសុទ្ធតែទីទល់ក្រ មិនអាចនឹងតំកល់ទុកសពនោះយូរ ដើម្បីធ្វើបុណ្យអ្វីផ្សេងទៀតឡើយ ហើយជម្ងឺចិត្តដែលជនបង្កគ្រោះថ្នាក់សងមកគ្រួសារជនរងគ្រោះនៅពេលនោះបានតែលុយ៨០០០រៀលប៉ុណ្ណោះ ។

លោក តាត សុខុន និង ភរិយា បង្ខំចិត្តទទួលយកលុយនេះទាំងក្តីឈឺចាប់ជាទីបំផុត ព្រោះមិនដឹងជាប្តឹងទាររជម្ងឺចិត្តបានការអី បើម្តាយជនមានពិរុទ្ធទៅអង្វរយំស្រែកសុំឱ្យអនុគ្រោះកូនគាត់ ដែលគ្មាពិតជាគ្មានចេតនាសោះឡើយ ម្ល៉ោះហើយជីវិតកុមារីអភព្វដែលថ្លៃស្មើតែ ៨០០០ រៀលនោះគាត់ទុកដូចជាកម្មផលព្រេងវាសនារបស់នាងទៅចុះ ។

ដំណើរជីវិតគ្រួសារ លោក តាត សុខុន និង អ្នកស្រី ឆាយ សារឿន នេះតែបន្តមកទៀត ប្រៀបបីដូចជាកូនទូកអុំកាត់រលកជលសារមហាសាគររហូតដល់ម៉ារីណាអាយុបានប្រាំបួនឆ្នាំ នាងចូលរៀនសាលា គឺរៀននៅសាលាភ្នំពេញជាមួយប្អូនប្រុស ម្នាក់ទៀតឈ្មោះ តាត សុផាណ្ណារិទ្ធិ ហៅអាទីទុយ និង បងស្រី បន្ទាប់ម្នាក់ទៀតឈ្មោះ តាត ស្រីពេជ្រ ឯបងមួយទៀតឈ្មោះ តាត ស្រីពៅ កាលដែលនាង តាត រំចង់ ហៅត្រប់ នៅរស់នាងរៀននៅកុលាបទី២ទួលស្លែងជាមួយគ្នា តែក្រោយពីបងមានគ្រោះថ្នាក់ដ៏សែនសោកស្តាយនោះមក ក៏ប្តូរមករៀននៅសាលាវត្តកោះវិញ ។

ចំពោះឈ្មោះ ម៉ារីណា នេះ បើតាមសំដីរបស់លោក តាត សុខុន ជាឪពុកបានបញ្ជាក់ថា ដើមឡើយលោកបានដាក់ឈ្មោះនាងថា តាត សុគន្ធ-បូរមី ដើម្បីឱ្យជួននឹងឈ្មោះបងៗ ពិសេសគឺបងប្រុសដែលរស់នៅអាមេរិក គឺ

តាត សុខុណ្ណារ៉ា ហៅ តាត សេគុនដូ ។

ហេតុដូច្នេះហើយ ទើបក្រោយព្រឹត្តិការណ៍ថ្ងៃ៥ធ្នូ ភ្លាម១ មានលេចឮឈ្មោះតាមកាសែតថា នារីរងគ្រោះដែលត្រូវគេជះ ទឹកអាស៊ីដនោះឈ្មោះថា តាន់ ឆាយសារីណា ហៅអាមុី បើសិនជាសម្គាសន៍ខាងម្ដាយ តែបើជួបសម្ភាសន៍ខាងឪពុកវិញ គឺ តាត ម៉ារីណា ហៅ ស្រីអូន ។

ពាក្យថា អាមុី១ គឺមកពីឈ្មោះ សុគន្ធបូរមី ។ អ្នកស្រី ឆាយសារឿន ដោយហេតុចង់ឱ្យឈ្មោះកូនមានលំនាំតាមឈ្មោះខ្លួនខ្លះ ក៏មួយពេលនោះបានប្រារព្ធហៅឈ្មោះកូនថា តាន់ ឆាយ សារីណា តែលោក តាត សុខុនមិនសូវយល់ស្រប ព្រោះកូនត្រូវតែប្រើត្រកូលខាងឪពុក ទើបគាត់កំណត់ឈ្មោះកូនជាផ្លូវការប្រាប់ពួកអ្នកកាសែតតាមឈ្មោះក្នុងបញ្ជីជាតិ ដែលចូលរៀន គឺ តាត ម៉ារីណា ហៅស្រីអូន ដោយគ្មានប្រែប្រួលអ្វីទៀតឡើយ ។

ដោយសារជីវភាពគ្រួសារទីទល់ក្រ ម៉ារីណា រៀនសូត្រក៏មិនសូវពូកែ និង មិនបានលូតលាស់វែងឆ្ងាយប៉ុន្មានឡើយ ។ នៅពេលនោះលោក តាត សុខុន តែងតែទៅជួយការងារថតវីដេអូជាមួយលោក គង្គ ប៊ុនឈឿន ដែលត្រូវជាប្អូនថ្លៃ ឯអ្នកស្រី ឆាយ សារឿន ដោយបានការឧបត្ថម្ភលុយកាក់ពីកូនប្រុសច្បងដែលនៅអាមេរិកខ្លះ ក៏បានរៀបចំធ្វើបាយមាន់លក់ ដើម្បីជួយទំនុកបំរុងគ្រួសារ និង ឱ្យកូនទៅរៀន ។

ម៉ារីណា រៀនដល់អាយុ ១៤ ឆ្នាំ រូបរាងនាងក៏បានបែកសាច់បែកឈាមស្រស់បំព្រងក្នុងរបៀបជាយុវវ័យស្រីជំទង់ ។ ដោយជីវភាពទល់ក្រពេក មិនអាចនឹងឱ្យកូនរៀនបន្តទៅមុខទៀតបាន អ្នកស្រី ឆាយ

សារឿន ក៏បានឱ្យកូនឈប់រៀន ដើម្បីមកជួយការងារលក់ដូរ ព្រោះកន្លងមកកាលកូននៅតូចៗ អ្នកស្រីក៏តស៊ូហត់នឿយខ្លាំងណាស់ហើយ ឥឡូវគាត់កាន់តែចាស់កម្លាំងក៏ថមថយ បានកូនធំៗត្រូវតែជួយកម្លាំងរកស៊ីខ្លះ ព្រោះនៅទីក្រុងភ្នំពេញនេះ បើមិនប្រឹងទាំងអស់គ្នាមុខជាមិនរស់ទេ ។

ហើយមិនមែនឈប់តែ ម៉ារីណា ម្នាក់ទេ បងៗនាងពីរនាក់ទៀតក៏ឈប់រៀនដែរ ទុកតែប្អូនប្រុសតែម្នាក់ប៉ុណ្ណោះឱ្យនៅរៀនបន្តទៀត ។

ក្នុងការជួយលក់ដូរម្ដាយ ម៉ារីណា ជាយុវតីដែលគួរឱ្យអាណិតស្រលាញ់ពន់ពេក ព្រោះនាងចេះបំរើភ្ញៀវ និង មានទឹកមុខញញឹមរីករាយស្រស់ស្រាយ ចេះហៅរកភ្ញៀវឱ្យចូលញាំុបាយជានិច្ច ។ បើពេលណាដែលម្ដាយនាងរវល់ ឱ្យនាងលក់ជំនួសម្ដងៗ នាងតែងមានចិត្តស្មោះត្រង់មិនកេងកិបម្ដាយ ដើម្បីបន្លំយកលុយទុកចាយផ្ដេសផ្ដាសឡើយ ។ បើសិនជានាងត្រូវការលុយទិញនំញាំុ និង ទិញអ្វីផ្សេងៗ នាងតែងសុំម្ដាយ ព្រោះនាងយល់ថាម្ដាយលំបាកណាស់ បើសិនជាចាយវាយផ្ដេសផ្ដាសមិនគិតមុខក្រោយមុខជាខាតបង់ខាតដើមហើយ ។

ចរិតស្លូតបូតស្មោះត្រង់របស់ម៉ារីណាជាទីពេញចិត្ត ពេញថ្លើមរបស់ម្ដាយ តែជួនកាលក៏មិនត្រូវចិត្តបងៗដែរ ព្រោះនាងទាំងពីរនោះរាងចាយដៃធូរលោយបន្តិច ហើយកាលណាបងៗនាងលួចកិបកេងលុយម្ដាយដែលលក់បានម៉ារីណាតែងតែនិយាយថា ÷

-បើបងៗនាំគ្នាយកចាយអីចឹង ម៉ែបានលុយអីទៅផ្សារទិញអីវ៉ាន់មកលក់ស្អែកទៀត ? . .

ជូនកាលសំដីនេះ ត្រូវបានស្វាគមន៍ពីរបីក្រញ៉ូលពីបង១មកវិញ ព្រោះគេថានាងចេះហៃហៃហួងហែងជំនួសម្ដាយពេក ។ ប៉ុន្តែ ម៉ារីណាមិនដែលខឹងសម្បារតបតពាក្យសំដីទៅបងវិញឡើយ នាងទ្រាំតែពីយំរៀងរហូត ។

មិនតែប៉ុណ្ណោះ ជូនកាលឪពុកមួរម៉ៅខឹងសម្បារមកពីណាពីណីក៏ម៉ារីណាតែងទទួលរងទារុណកម្មមិនសូវដែលលោះខានទៀត ។ ទោះយ៉ាងនេះក្ដី ក៏ម៉ារីណាមិនដែលហ៊ានប្រកែកប្រណាំងតបតវិញទេ នាងនៅតែគោរពស្រលាញ់ឪពុក និង ដាក់ខ្លួនឱ្យឪពុកស្ដីប្រដៅជានិច្ច ។

ពេលវេលាកន្លងទៅជាលំដាប់ . . .

អ្នកស្រី ឆាយ សារឿន លក់បាយមាន់បានប្រហែលមួយឆ្នាំ គឺនៅគ្រាដែល ម៉ារីណា មានអាយុ១៥ឆ្នាំ គាត់ក៏បែកគំនិតលក់បបរសនៅពេលយប់ និង លក់ទឹកក្រឡុកបន្ថែម ឯបាយមាន់លក់តែពេលព្រឹកមួយភ្លែត១ប៉ុណ្ណោះ ។ អ្នកស្រី ឆាយ សារឿន ដែលប្រកបមុខរបរថ្មីនេះ ដោយសំអាងលើកម្លាំងកូនជួយជ្រោមជ្រែង ព្រោះផ្ទះនៅកំពស់បួនជាន់ បើគ្មានអ្នកជួយជញ្ជូនអីវ៉ាន់ ដែលត្រូវលក់ចុះមកក្រោម និងសល់យកទៅលើវិញ នោះពិតជាមិនអាចទ្រាំទ្រួចឡើយ ។

ឯលោក តាត សុខុន ជាស្វាមី កាលប៉ុន្មានឆ្នាំមុនជាប់រវល់ទៅជួយថតវីដេអូបួនថ្ងៃមិនសូវបាននៅទំនេរទេ ប៉ុន្តែ ក្រោយឆ្នាំ១៩៩៥ដែលវិស័យសិល្បៈទី៧ខ្មែរត្រូវថមថយចុះ ព្រោះឥទ្ធិពលវប្បធម៌បរទេសចូលមកលុកលុយទន្ទ្រាន គាត់ហាក់ដូចជាចង់ដាច់អាជីពខាងផ្នែកនេះ ហើយត្រឡប់មកជួយការងារលក់ដូរជាមួយភរិយានៅផ្ទះវិញ ប៉ុន្តែគាត់ឈប់ប្រកបមុខរបរ

ជាជាងប៉ះកង់ម៉ូតូដូចមុនទៀតហើយ ។

ដំណើរជីវិតគ្រួសារកំសត់ពីមួយថ្ងៃទៅមួយថ្ងៃ ការលក់ដូរបាក់ដួចជាមិនមានការជឿនលឿនទៅមុខប៉ុន្មានឡើយ គឺគ្រាន់តែបានគ្រប់មាត់មិនសូវវេទនាដូចកាលប៉ុន្មានឆ្នាំមុននោះប៉ុណ្ណោះ ។

ថ្វីបើនាង តាត ស្រីពៅ មានប្តីមានកូនហើយក៏ដោយ ប៉ុន្តែបន្ទុកក្នុងគ្រួសារបាក់ដួចនៅតែធ្ងន់មកលើអ្នកស្រី ឆាយ សារឿនដដែល ទើបនាង តាត ស្រីពេជ្រ ជាកូនបន្ទាប់បានឆ្លៀតទៅរកការងារធ្វើផ្សេងវិញដូចជាទៅធ្វើជាអ្នកបំរើនៅក្រុមហ៊ុនស្រាបៀរប៊ុតវៃស្ស៊ែរជាដើម ។ ដូច្នេះអ្នកដែលនៅក្បែរកិតជាមួយម្តាយនិងបំរើភ្ញៀវជាប្រចាំនៅរាល់ពេលលក់ដូរ គឺមានតែម៉ារីណា ម្នាក់គត់ ដែលពេលនោះនាងក៏បានក្លាយជាបូផាមួយទង ដែលគាប់ភ្នែកអ្នកផងពន់ប្រមាណ ។

សម្រស់ដែលធម្មជាតិប្រទានមកឱ្យ ម៉ារីណា ក្នុងត្រកូល "តាត" នេះ មានភាពគួរឱ្យអ្នកឯទៀតច្រណែនណាស់គឺគ្រាន់តែ១៥ឆ្នាំប៉ុណ្ណោះនាងបានប្រែក្លាយពីទារិកាអង្គុយយំហៀរសំបោរចាំម្តាយឃ្លានបៅ នៅលើរានក្នុងខ្ទមចំការអំពៅនៅភូមិព្រែកក្របៅ មកជាកុលាបភ្នំពេញមួយទងដ៏មានសម្រស់ខ្ពស់ត្រដូច ដែលអាចស្ថិតនៅក្នុងលំដាប់ជាតារាវីដេអូ ឬ តារាចំរៀងទំនើប១បាន ។

ដោយសារ ម៉ារីណា ទទួលអំណោយផលនូវសម្ផស្សស្រស់ត្រកាលបែបនេះហើយ ទើបអ្នកដែលចេញចូលញ៉ាំបបរស ឬ ទិញទឹកក្រឡុករាល់១យប់ តែងគួចចិត្តគិតសរសើរមិនដាច់ពីមាត់ ហើយប្រុស១ ទោះជាកំលោះ

ឬមិនកំលោះក្ដី ក៏មមៃមកត់គួចលួចប្រតិពទ្ធស្នេហ៍លើរូបនាងគ្រប់ៗគ្នា ។

វាហាក់ដូចជាឆាប់ពេកណាស់ ដែលកុលាបមួយទងនេះ ស្ទើរមិនទាន់បើកស្រទាប់ស្រួលបួលផង ប្រែក្លាយទៅជាកំលាំងឆក់ទាញដ៏មិនចេះធុញទ្រាន់ពីបេះដូងកន្លង់នានា ប៉ុន្តែគ្មានសញ្ញាណាមួយដែលអាចឱ្យកន្លង់ទាំងនោះមានសង្ឃឹមថាបានក្រេបលំអងដ៏ស្រស់ខ្ចីរបស់នាងបានឡើយ ព្រោះលោក តាត សុខុន និង ភរិយា តែងស្តីប្រដៅអប់រំកូនជានិច្ចមិនឱ្យធ្វើអ្វីឱ្យខុសឆ្គងនឹងប្រពៃណីខ្មែរជាដាច់ខាត ។

គាត់តែងតែណែនាំពន្យល់កូនគ្រប់គ្នាថា ÷

-" នៅលើលោកនេះ គ្មានការងារណាដែលថោកទាបនោះឡើយ កុំឱ្យតែទៅកេងប្រវ័ញ្ចឆបោក លួចប្លន់គេ ! . . . ធម្មជាតិយើង ជាអ្នកក្រមានតែការរកស៊ីលក់ដូរបន្តិចបន្តួចនេះហើយ គ្រាន់បានកំរៃចិញ្ចឹមជីវិតយើងមិនត្រូវអៀនខ្មាស់ទេ គ្មានអ្នកណាឱ្យយើងស៊ីទេ បើយើងមិនខំប្រឹងរកខ្លួនយើង!! តែយើងត្រូវរក្សាសេចក្តីថ្លៃថ្នូរធ្វើយ៉ាងណា កុំឱ្យគេវាយតំលៃថាយើងនេះ ថ្លៃត្រឹមតែបបរសមួយចាន ឬ ទឹកក្រឡុកមួយកែវនោះឱ្យសោះ ! . . "

ដោយគោរពតាមសំដីណែនាំរបស់ឪពុកម្តាយយ៉ាងនេះហើយ ទើបម៉ារីណា នៅតែជាកម្មវត្ថុនៃអ្នកប៉ុនប៉ងផ្សេងៗ រហូតដល់មានកូនចៅកែខ្លះមានបំណងចង់ចូលមកដណ្តឹងថាទិញ ឡាន ឬ ទិញផ្ទះឱ្យ ប៉ុន្តែ លោក តាត សុខុន និង ភរិយាតែងតែមានទុទិដ្ឋិនិយមជានិច្ច ម្យ៉ាង ម៉ារីណា នៅក្មេងពេកមិនទាន់គ្រប់ការស្រួលបួល ម្យ៉ាងគ្រួសារទល់ក្រពេកនឹងស្រមៃចង់ឡើងឱ្យ

ស្មើរាជហង្ស ឬ ដួងតារានោះ មិនបានឡើយ ។

លោក តាត សុខុន តែងគិតថា គ្រួសារគាត់ក្រមែន តែមិនមែនចិញ្ចឹមកូនទុកលក់ដូចទំនិញទំណិញនោះទេ ។ លុយកាក់ មាសប្រាក់ អ្នកណាក៏ចង់បានដែរ ប៉ុន្តែ បើលុយកាក់មាសប្រាក់នោះ មិនមែនមកជាសុភមង្គលបរិសុទ្ធនោះពិតជាពិបាកនឹងទទួលយកណាស់ ។

នៅចន្លោះពេលជួយលក់ដូរឪពុកម្តាយ ម៉ារីណា តែងហាត់ច្រៀងជានិច្ច គឺនាងយកចិត្តទុកដាក់មើលគេសម្តែងនៅក្នុងកម្មវិធីទូរទស្សន៍ជាប្រចាំ ប៉ុន្តែ មិនមែនទៅហាត់រៀនពីអ្នកណា នៅកន្លែងណានោះទេ គឺនាងហាត់រៀនតែនៅក្នុងផ្ទះ និង សាកល្បងច្រៀងតាមការ៉ាអូខេម្តងៗប៉ុណ្ណោះ ។

ហេតុតែឧប្បនិស្ស័យនៃវង្សត្រកូល ដូចដែលបានរៀបរាប់តាំងពីដើមទីមកខ្លះហើយនោះ ម៉ារីណា ក៏រហ័សត្រង់ត្រាប់ចាប់បាន ទោះបីជានាងមិនទាន់មានបទពិសោធន៍ឡើងលើឆាកដូចគេក៏ដោយ ក៏នាងច្រៀងអាចស្តាប់បាន ដែលសង្ឃឹមថាអាចមានសន្ទុះរីកចំរើនទៅថ្ងៃមុខ ។

សម័យនេះ មានយុវនារី-យុវជនច្រើនណាស់ ដែលផ្សងសំណាងទៅជាអ្នកសម្តែងសិល្បៈច្រៀងរាំនៅលើឆាក ដើម្បីបានលុយកាក់មកចិញ្ចឹមជីវិត ។ ខ្លះក៏មានមោទនភាពលើជំនាញរបស់ខ្លួនពិតប្រាកដ តែខ្លះដែលមិនសូវពូកែ ក៏អាងលើរូបសម្ផស្សដូចជាបញ្ចេញដើមទ្រូង គល់ភ្លៅ ឬក្បាលពោះជាដើម ហើយខ្លះមិនពឹងលើទេពកោសល្យទាំងនោះប៉ុន្មានទេ ប៉ុន្តែចេះធ្វើខ្លួនជាអ្នករាំអមឆ្វេងស្តាំ លោតហក់ទៅតាមចង្វាក់ញាប់រង្វើល ហើយក៏បានដើរកំរៃទៅតាមហ្នឹងដែរ ។

យុវជន-យុវនារីទាំងអស់នោះ ខ្លះហាក់ដូចមិនទាន់យល់ថា សិល្បៈវប្បធម៌ជាអ្វីពិតប្រាកដទេ ឱ្យតែបានលុយក៏ចេះតែប្រឡូកខ្លួនទៅតាមគេបង្គាប់បញ្ជា ដោយហេតុថាបានសប្បាយផង បានកិត្តិយសល្បីល្បាញផង និងបានលុយផង ។ ប៉ុន្តែការដែលមិនបានយល់ដឹងពីអត្តសញ្ញាណនៃសិល្បៈវប្បធម៌ខ្មែរពិតប្រាកដនោះហើយ ទើបបានជាមានសិល្បករ សិល្បការិនីខ្លះធ្វើជាឧបករណ៍ ឃោសនាឱ្យមុខទំនិញរបស់ឈ្មួញដោយមិនដឹងខ្លួន ទាំងដែលមុខទំនិញនោះគ្មានតំលៃអ្វីបន្តិចសោះសំរាប់វប្បធម៌ជាតិ ។

តែការឡើងបង្ហាញខ្លួនមួយដងមួយកាល ឬ ក៏ញឹកញាប់នៅលើវេទិកាតន្ត្រីរបស់សិល្បការិនីទាំងឡាយនោះ ក៏ជាផ្លូវត្រួសត្រាយមួយសំរាប់ឱ្យគេទាក់ទាញយកនាងទៅច្រៀងនៅ តាមភោជនីយដ្ឋាន ឬ តាមរង្គសាលនានាដែរ ។

នេះជាមុខរបរគួរឱ្យស្រងេះស្រងោច និង ផ្សងព្រេងមួយរបស់យុវសិល្បករ-យុវសិល្បការិនីទំនើបថ្មី ។ យ៉ាងហោចណាស់ ក៏ពួកនាងអាចមានមុខ មានមាត់ ជាងពួកនារីប្រអប់រាត្រី ( BOÎTE DE NUIT ) ឬនារីដែលកាន់កំប៉ុងបៀរយ៉ែរសំរាប់ចាក់ឱ្យភ្ញៀវដែរ ហើយជួនកាលពួកនាងក៏មានភព្វសំណាង ត្រូវបានតាតាខ្លះដែលឆក់ឱកាសពីជំទាវ យកលុយមកចិញ្ចឹមធ្វើជាប្រពន្ធចុង ទិញឡាន ទិញផ្ទះឱ្យយ៉ាងងាយៗ ដោយគ្រាន់តែចេះធ្វើឱ្យពួកគាត់សប្បាយផ្តាំចាស់ប៉ុណ្ណោះ ។

គំនិតទាំងនេះ គឺជាការប្រមើលមើលរបស់លោក តាត សុខុន ទៅលើបរិវេណវាសនារបស់ ម៉ារីណា បុត្រីបណ្តូលចិត្តរបស់គាត់ ដែលគាត់

បាក់ដូចជាមិនចង់ឱ្យដើរតាមផ្លូវនោះសោះ ។ ពិតមែនហើយថា ម៉ារីណា មានរូបស្អាត បើគ្រាន់តែបណ្តោយឱ្យនាងផ្សងព្រេងនៅលើវេទិកាតន្ត្រី តែពីរបីលើក ទោះជានាងច្រៀងមិនសូវពិរោះក៏ដោយ ក៏ពិតជាមានអ្នកជួយឡូឡាសេជៀសមិនរួច ។ ហើយមិនយូរមិនឆាប់ នាងនឹងក្លាយទៅជាតារានេះតារានោះជាមិនខាន រួមទាំងមិនយូរមិនឆាប់ នាងនឹងក្លាយទៅជាអ្វីដូចដែលលោកបានគិត ព្រោះយុវនារីក្នុងលំដាប់គ្រួសារដូចជាគ្រួសារលោក មិនអាចយកឈ្នះទឹកប្រាក់បានគ្រប់កាលៈទេសៈនោះទេ ។

ដោយសម្លឹងមើលឃើញគ្រោះថ្នាក់ ដែលប្រៀបដូចជាខ្លាចាំត្របាក់អនាគតកូននៅមាត់ជ្រោះខាងមុខ លោក តាត សុខុន ព្រមទាំងអ្នកស្រី ឆាយ សារឿន បានព្យាយាមថែគ្រង និងបញ្ជៀសកូនមិនឱ្យដើរទៅតាមគន្លងដែលគាត់បានគិតនោះឡើយ ។

នេះមិនមែនមានន័យថា គាត់ស្អប់ខ្ពើមសិល្បៈវប្បធម៌នោះទេ ប៉ុន្តែបើទៅជាអ្នកចំរៀងពិរោះល្បីល្បាញពិតប្រាកដ ដូចអ្នកចំរៀងល្បីៗដទៃខ្លះនោះមានជាការអី ព្រោះគេពឹងពាក់លើទេពកោសល្យជំនាញរបស់គេ តែបើគ្រាន់តែច្រៀងបានលុំៗមិនអាចថតជាកាសែ្សត ឬ ស៊ីឌីបាននោះ ពិតជាជៀសមិនសូវរួចពីប្រើសំបករូបសម្បត្តិក្រៅជាមធ្យោបាយឡើយ ។

ដោយអតីតកាល ធ្លាប់ជាតន្ត្រីករកាន់វីយ៉ូឡុងនៅក្នុងវង់តន្ត្រីសាមគ្គីប្រចាំខេត្តបាត់ដំបង និង ធ្លាប់ចូលប្រឡូកក្នុងជីវភាពភ្លេងភ្លាត់នេះជាយូរមកដែរ លោក តាត សុខុន បាននិទស្សន៍ដឹងច្បាស់ថាមុននឹងទៅជាអ្នកចំរៀងអាជីពបាន តោងពឹងពាក់លើ ឧបនិស្ស័យពីកំណើតខ្ពង់ខ្ពស់ណាស់

ហើយឆ្លងកាត់ការហ្វឹកហាត់ និង សាកល្បងលត់ដំក្នុងការងារនោះមិនតិចឆ្នាំទេ ទើបអាចមានបទពិសោធន៍ច្រៀងស្តាប់យកជាការបានខ្លះ ។ ដូចនេះបើគ្រាន់តែហាត់ច្រៀងតាមកាសែតអូខេពិរោះបានពីរបីបទ នឹងចាត់ទុកថាចេះច្រៀងហើយនោះ ពិតជាមិនទាន់បានឡើយ ។

លោក តាត សុខុន តែងនិយាយប្រាប់កូនថា « បើបំណាច់សាងខ្លួនទៅជាអ្នកចំរៀង យ៉ាងហោចណាស់ក៏ឱ្យអ្នកស្តាប់សរសើរបានខ្លះថានាងនេះច្រៀងពិរោះមែន ឬ ពិរោះគ្រាន់បើដែរ ជៀសវាងគេរិះគន់ថា នាងនេះច្រៀងសម្លេងដូចទាកំប៉ា ឬដូចមាន់អួលអាចម៍ គ្មានបានជាការអីក្រៅតែពីបញ្ចេញវន្តផ្ចិត និង គល់ភ្លៅនោះឡើយ ដែលប្រការនេះអាចនាំដល់ភាពអាមាស់គ្រោតគ្រាត នៅក្នុងមុខអាជីពដ៏ផ្សងព្រេងប្រផុតប្រផើយ » ។

ផ្អែកលើទស្សនៈទាំងនេះហើយ ទើបប្រមុខគ្រួសារ "តាត" បានព្យាយាមថែរក្សាបរិស្ថានជីវិត ម៉ារីណា ឱ្យស្ថិតនៅក្នុងបរិយាកាសមួយល្អប្រសើរ . . . រហូត . . . រហូតដល់នាងបានអាយុ ១៦ឆ្នាំ ។ . .